**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អធិដ្ឋានពេញមួយយប់នៅជុំគិរី**
**ថ្ងៃទី០១ មិថុនា ២០១៧**

អត្ថបទទី១៖ កក ២២,៣០;២៣;៦-១១
ដំណឹងល្អ៖ យហ ១៧,២០-២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងស្តាប់រឿងដែលគេចាប់លោកប៉ូល ដោយសារលោកប៉ូលប្រកាសជំនឿលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ក្រោយមកលោកប៉ូលបានស្តាប់លឺថា **"ចូរក្លាហានឡើង អ្នកត្រូវតែផ្តល់សក្ខីភាពនៅក្រុងរ៉ូម ដូចអ្នកបានផ្តល់សក្ខីភាពអំពីយើងនៅក្នុងទីក្រុងយេរ៉ូសាឡឹមនេះដែរ"** នេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់គាត់។ ចូរក្លាហានឡើង ដើម្បីបន្តផ្តល់សក្ខីភាព ពេលគាត់ស្គាល់ព្រះយេស៊ូហើយជីវិតរបស់គាត់ទៅជាជីវិតថ្មី គាត់បានចាប់ផ្តើមប្រកាសដំណឹងល្អពីទីក្រុងយេរ៉ូសាឡឹម ក្រោយមកចេញពីភូមិមួយទៅភូមិមួយ ពីទីក្រុងមួយទៅទីក្រុងមួយ រហូតដល់ព្រះជាម្ចាស់បានជ្រើសរើសគាត់ដើម្បីទៅទីក្រុងរ៉ូម។ នៅសម័យនោះទីក្រុងរ៉ូមដូចជានៅកណ្តាលនៃពិភពលោក នឹងជាកន្លែងដែលមានអំណាចនៅក្នុងពិភពលោកទាំងមូល ដូច្នេះព្រះជាម្ចាស់បានជ្រើសរើសគាត់ឲ្យធ្វើដំណើរពីយេរ៉ូសាឡឹមដល់ទីក្រុងរ៉ូម មានន័យថាលោកប៉ូលមានសមត្ថភាពដើម្បីផ្តល់សក្ខីភាពយ៉ាងពិសេស។

ថ្ងៃនេះយើងមានកម្មវិធីសម្រាប់កូនក្មេងទូទាំងភូមិភាគភ្នំពេញ មានកូនក្មេងមកយ៉ាងច្រើនដែលមកពីកន្លែងផ្សេងៗ ដោយសារយើងមានមេក្រុមកាយឫទ្ធិដែលហៅគេព្រោះថាមេក្រុមកាយឫទ្ធិបានទទួលតួនាទីមួយដូចលោកប៉ូល ដើម្បីចែករំលែកជំនឿដែលយើងមានលើព្រះជាម្ចាស់ដែរ។ តាមរយៈកម្មវិធីកាយឫទ្ធិ ជាឱកាសមួយដើម្បីប្រមូលកូនក្មេងដូចលោកប៉ូលធ្វើពីដើម។ ថ្ងៃនេះ យើងបាននិយាយយ៉ាងច្បាស់លាស់អំពីសិទ្ធិរបស់កុមារ អំពីតម្លៃនៃជីវិតរបស់គេ។ ដូចលោកប៉ូល យើងជាគ្រីស្តទូត យើងត្រូវការមានសេចក្តីក្លាហាន ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមានអំណរសប្បាយ និងទទួលជីវិតពីព្រះយេស៊ូ។ យើងបានទទួលជីវិត យើងបានទទួលសេចក្តីសង្ឃឹម យើងបានទទួលសេចក្តីស្រឡាញ់នៅក្នុងការអធិដ្ឋានរបស់ព្រះយេស៊ូ ដែលបានអធិដ្ឋានសម្រាប់យើងឲ្យយើងទៅជាអង្គតែមួយ។ ព្រះយេស៊ូបានអធិដ្ឋាន ដើម្បីឲ្យក្រុមគ្រីស្តបរិស័ទទៅជាក្រុមគ្រួសារតែមួយដែលចេះ

ស្រឡាញ់គ្នាទៅវិញទៅមក។ ថ្ងៃនេះពាក្យអធិដ្ឋានរបស់ព្រះយេស៊ូ ដូចជាណែនាំឲ្យយើងមានបទពិសោធ ថ្ងៃនេះយើងមានស្ទើរតែគ្រប់ព្រះសហគមន៍ក្នុងភូមិភាគភ្នំពេញ បានប្រមូលកូនក្មេង ដើម្បីលេងជាមួយគ្នា សប្បាយជាមួយគ្នា បង្ហោះប៉ោងប៉ោងជាមួយគ្នាដោយអធិដ្ឋាន ដើម្បីឲ្យអ្នកដទៃទទួលស្គាល់អ្វីដែលយើងធ្វើសម្រាប់ទិវាកុមារអន្តរជាតិ។ នេះជាសញ្ញាសម្គាល់មួយ នៅក្នុងភូមិភាគភ្នំពេញរបស់យើង មានទាំងបងប្រុសបងស្រី លោកបូជាចារ្យ មេក្រុមកាយប្ញទ្ធិ បានយកចិត្តទុកដាក់ដោយសារយើងជាគ្រួសារតែមួយ។

យប់នេះ ពេលយើងអង្គុយអធិដ្ឋានរួមគ្នា ដើម្បីបង្ហាញថាពិតមែននៅក្នុងអង្គព្រះគ្រីស្តយើងជាគ្រួសារតែមួយ ដែលចេះជួយគ្នាទៅវិញទៅមក ដែលចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ដែលចេះផ្តល់កម្លាំងឲ្យគ្នាទៅវិញទៅមក។ យើងមកពីភូមិខុសៗគ្នា ប៉ុន្តែយើងចេះចូលរួមជាក្រុមគ្រួសារតែមួយ ពីមួយឆ្នាំទៅមួយឆ្នាំយើងបានទទួលបងប្អូនថ្មីជាច្រើន ដោយសារគេឃើញយើងជាគ្រីស្តបរិស័ទចេះស្រឡាញ់គ្នា ចេះជួយគ្នា ចេះស្វាគមន៍គ្នាទៅវិញទៅមក ណែនាំឲ្យបងប្អូនឯទៀតៗចង់ចូលនៅក្នុងក្រុមគ្រួសារយើង។ យើងចេះស្រឡាញ់គ្នា យើងចេះរួបរួមគ្នាជាធ្លុងតែមួយ ដោយសារយើងមានព្រះបិតា ព្រះបុត្រា ដែលស្រឡាញ់គ្នាយ៉ាងជិតស្និតបំផុតនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងមានព្រះជាម្ចាស់ដែលស្រឡាញ់យើង នៅក្នុងអង្គព្រះគ្រីស្តជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ណែនាំឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដល់កំពូល។ នៅថ្ងៃអាទិត្យខាងមុខ ដែលជាថ្ងៃព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ជាកម្លាំងមួយយ៉ាងពិសេស ដើម្បីឲ្យព្រះសហគមន៍របស់យើងខិតខំរួបរួមគ្នាជាក្រុមគ្រួសារតែមួយ ដោយលើកលែងទោសឲ្យគ្នាទៅវិញទៅមកជានិច្ច។ សព្វថ្ងៃយើងមានលោកបូជាចារ្យមកពីប្រទេសផ្សេងៗ ដែលមកដើម្បីបម្រើព្រះសហគមន៍នៅកម្ពុជា ប៉ុន្តែយើងសង្ឃឹមថាថ្ងៃអនាគតយើងនឹងមានបងប្អូនចេញពីទឹកដីរបស់យើងដើម្បីបម្រើព្រះសហគមន៍ក្នុងប្រទេសកម្ពុជា។

ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ និងទុកពាក្យអធិដ្ឋានរបស់ព្រះយេស៊ូដោយដឹងថាព្រះយេស៊ូនឹងអធិដ្ឋានសម្រាប់យើង ដើម្បីឲ្យយើងទីជាក្រុមគ្រួសារដែលចេះស្រឡាញ់គ្នា ដែលបើកចិត្តគំនិតទូលំទូលាយដើម្បីទទួលជីវិតដ៏បរិបូណ៌។ ថ្ងៃនេះយើងមានកូនក្មេងជាច្រើន នេះជាការអស្ចារ្យដែលព្រះជាម្ចាស់បង្ហាញតាមរយៈបងប្អូន ដើម្បីឲ្យព្រះនាមរបស់ព្រះអង្គទៅជាព្រះនាមដែលគេទទួលស្គាល់ ដែលគេគោរព និងស្រឡាញ់។

យើងអធិដ្ឋានសូមព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើងថែមទៀត ឲ្យយើងមានកម្លាំងកាយចិត្ត ឲ្យយើងមានជំនឿយ៉ាងរឹងមាំ ដើម្បីប្រកាសដំណឹងល្អ គឺពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ អាម៉ែន។